# ជីវិតកម្មករបណ្តែត

លំនាំបទៈ ទឹកហូរមិនហត់

១. ពាក្យដែលសន្យាបីខែប្រែក្លាយពេញសិទ្ធិ  កម្មករជឿពិតខិតខំប្រឹងប្រែងធ្វើការ
តែតាមការពិតថៅកែមានចិត្តកុហកមុសា  ខំរកវិធីយ៉ាងណាចាប់កំហុសនិងបណ្តេញចេញ ។

២. កម្មករបណ្តែតមិនដែលហូបឆ្អែតម្តងទេ  ព្រោះអីប្រាក់ខែបានតែសាមសិបដុល្លា
ព្យាបាលជំងឺថ្លៃផ្ទះទឹកភ្លើងនិងម្ហូបអាហារ  ពេលដាច់ខែចិត្តឈឺផ្សារបានប្រាក់ឯណាផ្ញើទៅស្រុក ។

បន្ទរ នៅក្នុងមាត្រា នៃច្បាប់ការងារកម្ពុជាកម្មករគ្រប់គ្នា ពេញសិទ្ធិក្រោយពេលបីខែ
តែរូបខ្ញុំត្រូវគេបញ្ឈប់ដោយសារ  មេការសាមាន្យឫស្យា បំផ្លើសថាខ្ញុំល្មើសនិងច្បាប់ ។

៣ សម្រែកកម្មករស្រែកអង្វររកជំនួយ  ឲ្យសង្គមជួយដោះស្រាយបញ្ហាយើងផង
ឱ!កម្មករអើយក្រោកឡើងសាមគ្គីរួបរួមកំលាំង តស៊ូប្រយុទ្ធប្រឆាំងការជិះជាន់និងរើសអើង។



កម្មវិធីកម្មកររោងចក្រកាត់ដេរ ©២០០៥

និពន្ធនិងច្រៀងដោយកម្មកររោងចក្រកាត់ដេរ